វិទ្យាល័យ	secondary school, lycée
វិទ្យាសាស្ត្រ	science
វិទ្យុ	radio
វិទ្យុទូរទស្សន៍	television
វិធាន	plan, program; act
វិធានការ	action taken to solve a problem, measures, steps
វិធានការរយៈពេលខ្លី	short term measure
វិធានការរយៈពេលវែង	long term measure
វិធី	method, style
វិធីសាស្ត្រ	methodology
វិន័យ	discipline
វិនាទី	second (unit of time)
វិនាស	to be destroyed, be vanished; to vanish
វិនាសកម្ម	destruction, devastation

វិនិច្ឆ័យ	to judge
វិនិយោគ	investment
វិបត្តិ	change, crisis, event
វិបត្តិនយោបាយ	political crisis
វិបត្តិសេដ្ឋកិច្ច	economic crisis
វិបល្លាស	perturbation, perversion
វិបាក	incident (with negative consequences)
វិភាគ	dividing, part, share
វិភាគទាន	alms, charity, contribution, donation, portion
ធ្វើវិភាគទាន	to contribute, sacrifice
វិមាន	edifice, monument
វិមានឯករាជ្យ	Independence Monument
វីរៈ (វីរ)	audacious, brave, strong, tough, ingenious, high, noble, valuable
វីរជន	hero, someone of high status; a notable member of the elite
វីរបុរស	founding father, important figure in the history of a country hero
វិរុទ្ធ	different, incorrect, wrong
អក្ខរាវិរុទ្ធ	orthography, spelling
វិល	to return, spin
វិលមុខ	to be dizzy, evolution
វិវឌ្ឍន៍	evolution
វិវាទ	to have a quarrel (lit.); dispute at law, suit
វិស័យ	field, range, scope
វិសាខ	name of the 6th lunar month (mid-April to mid-May) (a.w. ពិសាខ)
វិសាមញ្ញ	extraordinary
វិសុទ្ធ	perfect, pure
វិសុទ្ធកម្ម	purification
វិសុទ្ធភាព	perfection
វិស្វកម្ម	engineering
វិស្វករ	engineer
វិស្សមៈ	recess
វិស្សមកាល	vacation, recess

វិហារ	church, sanctuary, temple
វីឡា (វិឡា)	stucco or stone house, villa, single-family home
វឹះ	almost
វឹះតែ	almost
វុ	exclamation indicating regret
វុ	see វើយ
វូក	to turn upside down all over, to spread thin, thin
វូកវរ	confusedly
វីយ៉ូឡុង	violin
វាយ	to beat, stir
វាយវរ	to be in trouble, be in difficulties
វង់ស៊ុង	to deteriorate into confusion and drunkenness
វុ	uh! (= វើយ) (intimate)
ទៅណាវើយ?	Where are you going?
ស៊ីអីវុ?	What are you eating?
វើកៗ	slowly
វើយ	indicates urging or warning (familiar)
វៀច	crooked, dishonest, not straight
វៀចវេរ	twisted
ចិត្តវៀច	crooked mind
វៀតណាម	Viet Nam
វៀតណាមូបនីយកម្ម	Vietnamization
វៀរបង់	to discard, give up, throw out
វេ	Hué (ancient Vietnamese capital)
វេច	to fold over, pack, pack and wrap into a package
វេជ្ជបណ្ឌិត	doctor of medicine
វេញ	to twine
វេន	turn (in line)
ដល់វេន	it's (your) turn
ផ្លាស់វេនគ្នា យកវេនគ្នា	to take turns
វេទនា	misery, suffering
វេទនា	miserable, suffering
វេទិកា	rostrum
វេទិក	gratitude
វេយ្យាករណ៍	grammar
វេរគេន	to offer, give to clergy (formal)
វេរភត្តាហារ	food for monks
វេលា	time (formal) (= ពេល)
វេះ	to evade, play hooky
គេចវេះ	to avoid being seen
វែក	to make apart, part, separate, split; ladle
សិតសក់វែកចំហៀង	to part hair
វែកចំហៀង	to part hair
វែកញែក	to analyze, explain by breaking a problem into components
វែកពួក	to separate; to be partisan; to find (fig.)
វែង	long (said of things)
វែងឆ្ងាយ	far, far ahead, into the future
វែងអន្លាយ	long and continuous
វ៉ែនតា	glasses
វោហារ	elocution
វាំង	palace
វាំងនន	curtain
វះ	to cut open, to operate (surgery)
វះកាត់	to perform an operation
វះពោះត្រី	to cut a fish

ស

ស	white
សក្បុស	virgin white
សក្លីន	clean white, cotten white
សស្គុស	virgin white
ដីស	chalk
ស្រាយឲ្យឃើញ	to demonstrate, prove show
សក	to peel; to shed skin or shell
សកសំបក	to peel skin or bark
ក្ដាមសក	soft shell crabs
ចាស់សក	to be immortal
ស័ក	time, the progression of years, era
សករាជ	era
គ្រិស្តសករាជ	Christian era
ពុទ្ធសករាជ	Buddhist era
សក់	hair (on the head)
សក់កន្ដាញ់	kinky hair
សក់ក្រញាញ់	kinky hair
សក់រួញ	undulated hair, wavy hair
សក់ស្កូវ	gray hair
សក់អង្កាញ់	curly hair
កាត់សក់	to get or give a haircut
កោរសក់	to shave the hair (of the head)
ចងសក់	to tie the hair up in a chignon
ជើងសក់	hairline, sideburn
បួងសក់	to tie the hair up in a bun behind the head
សិតសក់	to comb the hair
អ៊ុតសក់	to give a permanent (curl)
ស៊ក	to insert
ស៊កសៀត	to insinuate, to instigate
សកម្ម	active
សកម្មភាព	activity
យ៉ាងសកម្ម	actively
សក្ការ	respect, worship, gift to a superior, offering
សក្ការបូជា	offering, sacrificial object
សក្ខី	witness (s.w. សក្សី)
សក្ខីភាព	evidence, proof
សក្តិ	to tattoo, tattoo, grade, rank, stripe
សក្តិបី	captain
សក្តិភូមិ	feudal
សក្តិសិទ្ធិ	holy, sacred, effective
ការសក្តិសិទ្ធិ	effectiveness
សាក្សី	witness
សគុណ	favor, obligation
ជំពាក់សគុណគេ	to owe an obligation
សង	to repay, return (something), to substract
សងគុណ	to repay a moral debt
សងសឹក	to retaliate, revenge
ល្បែងស៊ីសង	gambling
សងខាង	both sides
៣ សង ២ នៅសល់ប៉ុន្មាន?	How much is 2 subtracted from 3?
សង់	to construct, build
សង់ខ្យា	custard, pudding

សង្កត់	to press, put (weight) on
សង្កត់ក	to press the neck against something; to oppress
សង្កត់សង្កិន	to extort, to oppress
សង្កថា	speech
សង្កាត់	a political division of a town or a district
សង្កិន	to grind by milling action, flatten, run over
សង្កើច	bedbug
សង្កេត	to observe
សង្ក្រាន្ត	arrival (formal); departure; completion of a solar year; new year holiday
សង្ខាង	both sides
សង្ខារ	life (literary)
សង្ខេប	to summarize
សង្ខេបនិយាយទៅ	in short
សេចក្តីសង្ខេប	summary
សង្គម	society
សង្គមកិច្ច	social affairs
សង្គមនិយម	socialism, socialist
សង្គមសាស្ត្រ	sociology
សង្គហៈ	salvation; aid, assistance, help
សង្គហក្រោះ	devoted to social welfare
សង្គ្រាជ	superior of a wat, abbot
សង្គ្រាម	war
សង្គ្រាមចិត្តសាស្ត្រ	psychological warfare
សង្គ្រាមបដិវត្តន៍	revolutionary war
សង្គ្រាមសកលលោក	world war
សង្គ្រោះ	to help, save; help, saving
សង្គ្រប	to pounce upon in order to catch
សង្ឃ	member of the Sangka, a Buddhist monk
សង្ឃទាន	a ceremony in which monks are invited to the house so that a person who can not get to the wat can offer food
លោកសង្ឃ	monk
សង្ឃឹម	to hope; hope
សេចក្តីសង្ឃឹម	hope
អស់សង្ឃឹម	to be hopeless, despair
សង្រេង	to be sad, be unhappy
សង្វាក់	rhythm, timing
សង្វាត	to try hard, persevere
សង្វត	shrunken, tough
សង្វេគ	to feel pity; sad
សង្វេគយល់	to feel empathy
សង្ស័យ	to suspect; to be suspicious, be fishy, be skeptical
មន្ទិលសង្ស័យ	to suspect
មានការសង្ស័យចំពោះរឿងនោះ(គ្រោះថ្នាក់)	There is something fishy about that accident.
សង្សារ	girl or boy on steady date ; love
សង្ហា	arrogant; proud, showing off
សង្អារ	a large, black ant
សច្ចៈ	truth
សច្ចធម៌	the truth
សច្ចា	to vow, swear
សច្ចាប្រណិធាន	to take an oath, be sworn in
ពាក្យសច្ចា	reliable words, true words
សញ្ចេតនា	preference
សញ្ញា	signal, sign, symbol
សញ្ញាភ្លើង	flare; light signal
សញ្ជាតិ	nationality
សញ្ញាប័ត្រ	certificate (diploma) (formal)
សញ្ញាប័ត្រជាន់ខ្ពស់	advanced degree diploma
សញ្ញាប័ត្រមធ្យមសិក្សា	high school diploma
សណ្ដ	mouth
ដីសណ្ដ	delta (geography)
សណ្ដាប់	manner, method, order, system
សណ្ដាប់ធ្នាប់	conduct, manner

សណ្ដូក	to stretch, be extended
សណ្ដូកទៅរក	to stretch, to lie toward
សណ្ដែក	bean, pea
សណ្ដែកដី	peanut
សណ្ដែកបណ្ដុះ	bean sprout
សណ្ដែកព៉ាយ	soybean
សណ្ដោង	to haul, to drag something, tow
សណ្ឋាគារ	hotel, place to stay
សណ្ឋាគារខេត្ត	quarters for guests of the provincial government
សណ្ឋាន	aspect, attitude; phase
សណ្ឋារកិច្ច	hospitality
សត:	hundred (Sanskrit)
សតវត្ស	century
សតិសម្បជញ្ញៈ	awareness, mind
សតិសារម្មណ៍	conscience
សត្រូវ	enemy
ខ្មាំងសត្រូវ	enemy
បង្កើតសត្រូវ	to create an enemy out of a friend
សត្វ	animal, being (human or animal)
សត្វតិរច្ឆាន	beast
សត្វពាហនៈ	draft animals
សត្វលោក	being (esp. human)
សត្វល្អិត	insect
សត្វល្អិតល្អួច	insects
សត្វស្លាប	bird
សទ្ធម្មបុណ្ឌរីក	name of a Mahayana Buddhist scripture
សទ្ធា	belief esp. in merit, sin and karma; generous
សទ្ធាចិត្ត	believing in merit, sin, and karma; generosity
សន្ឋាន	aspect, phase; faction
សន្តាន	breed, family
សន្តានចិត្ត	attitude, intention, state of mind
សន្តិ	peace
សន្តិភាព	peace
សន្តិភាវូបនីយកម្ម	pacification
សន្តិសុខ	safety, security
សន្តិសុខជាតិ	national security
សន្តោស	gladness, happiness; acquital
សន្ទនា	to discuss a matter
សន្ទុះ	moment, while; a burst of speed
សន្ទូង	young rice plant
សន្ធឹក	a lot, many
សន្ធឹកសន្ធាប់	lots, many
សន្ធឹង	to extend
សន្និដ្ឋាន	to assume, conclude
សន្និបាត	conference, convention, debate
សន្និសីទ	conference
សន្មត	to assume, conclude; to consider; to promise
សន្យា	to promise
សន្លប់	to have fainted, be inconscious, pass out, faint
សន្លឹក	sheet (of paper, leaf)
សន្លឹកឆ្នោត	ballot
សន្សំ	to save
សប់	to inflate, pump air
សប់កង់	to inflate a tire
សប្ដិ	dream
កាត់សប្ដិ	to interpret a dream
យល់សប្ដិ	to dream
សប្ដាហ៍	week (formal)
សប្បាយ	agreeable, happy, pleasant, nice
សប្បាយចិត្ត	content, proud
សប្បុរស	compassionate, generous, kind
សប្បុរសធម៌	compassion, generosity, goodness, kindness
សព	body, cadaver, corpse (formal); the late...
តាំងសព	to display a corpse in its coffin before a funeral

សពលោកសុខ	the late Mr. Sok
សព្វនាម	pronoun
សព្វ	each, every; all full, thoroughly
សព្វខ្លួន	separately
សព្វគ្រប់	adequate, all, completely, entirely
សព្វថ្ងៃ	at present, nowadays
សព្វថ្ងៃនេះ	nowadays, presently
សព្វតែ + n.	even + noun
សព្វបើ	just, only
សព្វព្រះទ័យ	to be pleased, be satisfied (royal)
សព្វមុខ	of every sort
សព្វាង្គកាយ	body (literary)
សព្វាវុធ	weapons of every sort
សភា	assembly, congress, legislative house, parliament
សភាចោទប្រស	prosecutor
សភាព	appearance, state of being, aspect (a.w. សភាវៈ)
សម	to be becoming, be appropriate, be proper; to fit well, fork
clause + សម + clause + ផង	in fact..., in addition, furthermore
សម + clause + ផង	at the same time as, in addition to the fact that
សមមុខ	to deserve
សមរម្យ	good, logical (somewhat formal)
ការសមរម្យ	decency
សមស្របនឹង	appropriate to, fitting for
សមសួន	appropriate, becoming
សមហេតុសមផល	appropriate
សមណៈ	one who follows the dharma, who strives to live in accord with Buddhist principles, a monk
សមត្ថៈ	capable
សមត្ថកិច្ច	area of capability, area of competence
សមត្ថភាព	ability, capacity, competence
សមភាព	equality, state of being equal
សម័យ	era, modern, time
ភ្លេងសម័យ	modern time
សម័យថ្មី	modern music
សមរភូមិ	battlefield
សមាគម	association, club
សមាជ	(congressional) session
សមាជិក	member (male)
សមាជិកា	member (female)
សមាទាន	to except; to express submission; to give
សមាធិ	to purify, devotion, self possession
សម្មាធិ	to purify onself, overcome passion
សមាធិកម្មដ្ឋាន	worship
សមាសភាព	coalition
សមិទ្ធិ	construction, realization
សមុច្ឆេទ	to cut off, give up, throw out
សមុទ្រ	sea
សមុហបញ្ជី	keeper of vital statistics (=ក្រឡាបញ្ជី)
សម្គាល់	to know, recognize, single
សម្ងាត់	secret (adj.)
ការសម្ងាត់	secret (n.)
សម្ងំ	to brood, condone, remain silent in the face of wrong
សម្ដេច	nobleman, prince (a title that can be given to people of non-royal birth)
សម្ដេចព្រះសង្ឃរាជ	a patriarch of one of the two Cambodian Buddhist orders
សម្ដេចឪ	'Papa Prince' (affectionate title for Prince Sihanouk)
សម្ដែង	to express

សម្បជញ្ញៈ	alertness, awareness, conscience
សម្បត្តិ	asset, property, belongings, wealth
សម្បថ	oath, pledge (= សំបថ)
សម្បទា	full, plenty, abundance (lit.), aptitude
សម្បាច់	to receive as one's responsibility
រួមសម្បាច់	in common
សម្បុរ	complexion, skin color
សម្បុរសាច់	complexion
សម្បូណ៌	abundant, plentiful
សម្បូរ	Sambaur (place name in Kratie province)
សម្បូរណ៍	abundant, plentiful
សម្បូរណភាព	abundance
សម្បើម	terrible; extremely, terribly
សម្ផស្ស	charm
សម្ព័ន្ធ	ally (n.)
សម្ពោធិ	enlightenment
សម្ភារៈ	material, supplies
ខាងផ្លូវសម្ភារៈ	materialistic
សម្ភាសន៍	interview
សម្មា	correct, good, true (lit.)
សម្មាសម្ពោធិញាណ	enlightenment
សម្រក់	to emit drops, shed
សម្រស់	charm, prettiness
សម្រាក	to relax, rest
សម្រាត	to undress someone, strip someone
សម្រាន្ត	to sleep (formal)
សម្រាប់	for, used for; set (a.w. សំរាប់)
សម្រាម	garbage
សម្រាយ	unimportant, trivial; ordinary
ពាក្យសម្រាយ	everyday words
សម្រាល	to make lighter, lighten; to give birth
សម្រុក	to force one's way in without thinking of any consequences, assault; to snore
សម្រុះសម្រួល	to arbitrate, ease, reconciliate, smooth the way
សម្រួច	to sharpen (point)
សម្រួល	to ease, simplify
សម្រើប	to excite; excitement
សម្រេច	to decide, make a decision
សម្រែក	shout, scream (n.)
សម្ល	soup, stew
សម្លកកូរ	a kind of Khmer stew with many vegetables
សម្លគ្រឿង	a spicy stew
សម្លម្ជូរ	sour stew
សម្លាញ់	friend, love, mutual friendship
សម្លាប់	to kill
សម្លាប់ខ្លួនឯង	to commit suicide
សម្លឹង	to look at, stare at
សម្លុក	to intimidate
សម្លេង	voice, sound; vote (n.) esp. in a voice vote
សម្លេងឆ្នោត	vote (n.)
សម្លេងសហរដ្ឋអាមេរិក	Voice of America
សម្អុយ	to cause to stink; rail at, slander, spread bad things about someone, use bitter or abusive language
ស៊យ	to be unlucky; bad luck
សរសើរ	to congratulate, praise to encourage
សូមសរសើរ	congratulations!
សរសេរ	to write
សរសៃ	nerve, tendon
សរសៃ	string, thread, vein
សរសៃឆ្អឹងខ្នង	spinal cord
ច្រឹសរសៃ	to massage
ស.រ.អា	= សហរដ្ឋអាមេរិក
សរុប	to summarize
សរុបទៅ	in short, in brief

សរុបសេចក្ដី.ទៅ	to make a long story short; in short
សល់	to be left over, remain; remains
ស.រ	= សករាជ
សវន	to listen (literary)
សវនកិច្ច	audience (with a dignitary)
សវនដ្ឋាន	auditorium (formal)
សសរ	column
សសរទ្រូង	a principal column
សសរស្តម្ភ	a kind of column found in temples
សសៀរ	to approach
សហ	untied
សហករណ៍	co-operative (organization)
សហការណ៍	to cooperate, work together
សហការី	colleague, co-worker
សហគមន៍	community
សហគ្រាស	enterprise
សហជីព	syndicate
សហជីវិន	camrade
សហប្រជាជាតិ	united nations
សហប្រតិបត្តិការ	cooperation
សហព័ន្ធ	union, federation
សហព័ន្ធម៉ាឡេស៊ី	Malaysia Federation
សហភាព	union
សហភាពសូវៀត	Soviet Union
សហរដ្ឋ	united states
សហរដ្ឋអាមេរិក	United States of America
សហសុខា:	joint welfare
សំដែងឲ្យឃើញ	to demonstrate, prove, show
សា	to turn something over, to bring in something exposed to the sun
សា	to do again, repeat
សាជាថ្មី	to do again, repeat; again, another time
សាក	to test, try, sample
សាកល	universal; universe
សាកលលោក	the whole world, universe
សាកលវិទ្យាល័យ	university
សាក់សូហ្វូន	saxophone
សាក្សី	witness
សាខា	branch, affiliate(d)
សាខាបុគ្គល	personal branch
សាគរ	ocean (formal)
សាង	to build (formal)
សាងផ្នួស	to become a monk, give up worldly life (= បួស)
សាច់	flesh, meat; muscle
សាច់ក្រក	sausage
សាច់គាត់ល្អណាស់	Her skin is smooth.
សាច់ចៀម	lamb (mutton)
សាច់ជ្រូក	pork
សាច់ឈើ	wood
សាច់ញាតិ	relatives
សាច់ដុំ	muscle
សាច់មាន់	chicken
សាច់សាលោហិត	relatives
សាទរ	to agree with pleasure; to be courteous and nice, respect
សាទុក្ខមិនសុខចិត្ត	to complain, bring suit
សាធារណ:	public
សាធារណការ	public works
សាធារណជន	the public
សាធារណនិយម	republicanism
សាធារណរដ្ឋ	republic
សាធារណរដ្ឋសហព័ន្ធ	federal; federation
សាធុ	good, well done!; bravo, no big loss, O.K.; amen; hello (said of child to elder)
សាធុការ	act of saying សាធុ
សាធុទៅចុះ:	(that's your trouble)
សាធុលោកតា (គាត់)	Say hello to him; shake hands with him

សាន្ត	calm
សាន្តភាព	peaceful
សាប	to sow (for eventual transplanting); bland, flat (taste)
សាបមាត់	mouth tastes like cotton
សាប៊ូ	soap
សាមគ្គី	cooperation, team work, unity
សាមគ្គីភាព	solidarity
សាមញ្ញ	general, ordinary
សាមណេរ	a novice monk
សាមសិប	thirty
សាមី	the one concerned, the subject
សាយ សាយ	to diffuse, spread about; evening, dusk (formal)
សាយណ្ហ	dusk (literary)
សាយភោជន៍	banquet (formal)
សារ	core, importance, usefulness; letter, message (a.w. សារៈ)
សារពានរឿង	table of contents
សារពត៌មាន	information, news, newspaper, press
សារមន្ទីរ	archive, museum
សារមន្ទីរជាតិ	national museum
សារៈសំខាន់	essence, importance
សារវន្ត	essential, fundamental, important
អ្នកនាំសារ	messenger
សារពើ	of all kinds
សព្វសារពើ	of all kinds
សារភាព	to admit; act of admitting one's fault
សារាចរ	document for circulation, memorandum
សារិកាកែវ	mynah bird
សារុង	sarong
សាល	hall
សាលក្រម	letter announcing verdict of court, verdict
សាលព្រឹក្ស	a banyan tree (under which Buddha was born and died)
សាលា	hall, school
សាលាក្រុង	city hall
សាលាក្រមបទេស	court that reviews decisions of lower courts and refers cases with which it is dissatisfied to the appeals court
សាលាឃុំ	district hall
សាលាជាន់ខ្ពស់	institution of higher learning
សាលារៀន	school
សាលាជំបង	trial
សាលាវិចិត្រសិល្បៈ	the school of fine arts
សាលាលហុ	trial court
សាលាលហុយន = សាលាលហុ	
សាលាវិនិច្ឆ័យ	supreme court
សាលាសង្កាត់	town hall
សាលាស្រុក	district hall
សាលាឧក្រិដ្ឋ	criminal court
សាលាឧទ្ធរណ៍	court of appeals
សាលីស៊ីឡាត	silicylate (from silicylic acid)
សាវា	capricious
សាសនា	religion
សាសនាព្រាហ្មណ៍	Brahmanism, Hinduism
គ្រិស្តសាសនា	Christianity
ពុទ្ធសាសនា	Buddhism
សាស្ទីន	a kind of cloth that keeps crease well, shark skin cloth
សាស្ត្រ	study of, science of
គណិតសាស្ត្រ	mathematics
ប្រវត្តិសាស្ត្រ	history
ភូមិសាស្ត្រ	geography
សាស្ត្រា	palm leaf inscription
សាស្ត្រាចារ្យ	professor
សាហាយ	lover
សាហាវ	fierce, savage, wild
សាឡាត់	lettuce, salad

សាឡាត់បូកគោ	lettuce
សាឡុង	couch, sofa, living room
សាអ៊ីវ	soy sauce
ទឹកសាអ៊ីវ	soy sauce
សិក្ខា	study (a.w. សិក្សា)
សិក្ខាបទ	a portion of Buddist monastic discipline
សិក្សា	to study (formal)
ការសិក្សា	education
ការសិក្សាជាន់ខ្ពស់	higher education
សិត	to comb (hair), to strain) discard
សិតសក់	to comb
សិតតែ	exclusively, only (= សុទ្ធតែ)
សិទ្ធត្ថ	Siddhartha (given name of the Buddha)(= សិទ្ធាថ៌)
សិទ្ធិ	a right
សិន	first, for the time being, for a while
សិប្បៈ	skill
សិប្បកម្ម	craftsmanship
សិប្បករ	craftsman
សិរិមតៈ	Sarimatak (name of a Khmer leader)
សិរីលង្កា	Sri Lanka (Ceylon)
សិរីសួស្ដី	good health and good fortune
សិរីសោភ័ណ	Sisophon (place name in Battambang province)
សិលា	stone (literary)
សិលាចារឹក	inscriptions in stone
សិល្បៈ	art
វិចិត្រសិល្បៈ	fine arts
សិស្ស	pupil, student
សិស្សានុសិស្ស	students (collectives)
សី	shuttlecock
ស៊ី	to eat, consume (intimate style in the city, and ordinary style in the country); to take a bribe
ស៊ីកោរ	to take advantage; to cheat
ស៊ីគ្នា	to be in harmony, be appropriate to one another, harmonize; to match
ស៊ីឈ្នួល	to go into domestic service; to take a job (usually menial)
ស៊ីសុយ	to take a bribe
ស៊ីលើ	to take advantage
ស៊ីសង(តែ)	to depend on whether...or, it depends on; to be up to; to gamble
ល្បែងស៊ីសង	gambling
ស៊ីសំណូក	to take a bribe
ស៊ីសាំង	to consume gas
ស៊ីក្លូ	cyclopousse, pedicab
ស៊ីញ៉េ	to sign
សីតុណ្ហ	cold and hot
សីតុណ្ហភាព	temperature
ស៊ីម៉ង់	cement
សីហ	city, country (lit.)
សីល	religious rule, precept; grace, holiness, piety
សីលធម៌	manners and behavior that lead one to do good and avoid bad; precepts of rightiousness; holiness and virtue of people
កាន់សីល	to observe religious precepts (including abstinence)
ថ្ងៃសីល	day of abstinence and religious observance
សុំសីល	to go to the wat on a day of abstinence to take food to the monks and participate in prayers
ស៊ីវិល	civilian
សីហនុ	Sihanouk
សីហា	August
ស៊ីផ្លេ	horn, whistle
សឹក	to leave the monkhood
សឹក	to erode, wear out; to be loose; military, pertaining to war
សឹង	to sleep (clerical); almost

ស្ទើរតែ	almost
ស្ទើរស្លាប់	extremely, really, very (colloquial)
សឹម	later, then
ញ៉ាំបាយសិនសឹមរៀន	Eat first, then study
សឺទីហ្វីកា	certificate of elementary school completion (French: certificat)
សឺងង៉ុកថាញ់	Son Ngoc Thanh (name of an antigovernment Cambodian politician)
សឺមីស	Shirt (French: chemise)
សារី	pear
សូកូឡា	chocolate
សុខ	to be healthy, be fine; to be safe, be secure, be peaceful
សុខចិត្ត	to be willing, be satisfied; to agree; to sacrifice
សុខដុម	happy, safe, well
សុខទុក្ខ	state of one's personal affairs
សួរសុខទុក្ខ	to ask after someone, say hello to
សុខភាព	health
សុខសប្បាយ	How are you?
សុខសម្ផស្ស	well-being
សុខសាន្ត	calm, peaceful
សុខាភិបាល	health administration, health care
សុខុមាល	healthy, well off
សុខុមាលភាព	health, state of being healthy
សុខោទ័យ	Sukjothai (name of the first Thai Kingdom)
សុគត	to die (clerical)
សុគតិ	good action, just behavior (literary)
សុគតិភព	Heaven (literary)
ស៊ង	carton (cigarette)
បារី១ស៊ង	a carton of cigarettes
សុច	gnat
សុចរិត	honest
ការសុចរិត	honesty
សុចរិយា	good character
សុជីវធម៌	courtesy, manner
សុញ	to run out of ideas, be unimaginative
សុដន់	breast (human)
ស៊ុត	egg
សុទ្ធ	pure
សុទ្ធតែ	all, exclusively
សុទ្ធសាធ	pure, real, true; absolutely
សុទ្ធស្ទើរតែ	almost all
សុន្ទរ	good, melodic; attractive, lovable, pleasing
សុន្ទរទាន	a good, welcome gift
ស៊ុប	soup
ស៊ប់	completely, really
	to infiltrate, be saturated
គមិនទាន់អង្គុយស៊ប់ទេ	He hasn't really sat down yet.
ស៊ប់សួន	to infiltrate, be saturated
សុបិន	to dream; dream
សុពលកម្ម	validation (literary)
សុភ:	good
សុភមង្គល	good fortune, happiness
សុភវិនិច្ឆ័យ	common sense
សុភា	short for សុភាចារបុរស ; court room; prosecutor
សុភាចារបុរស	prosecutor, prosecuting attorney
សុភាព	modest, polite
សុភាសិត	proverb, saying
ស៊ុមគ្រលុំ	to collatorate; hanky-panky
សុរា	liquor
សុរិយ	sun (literary)
សុរិយវង្ស	Sur. Dynasty (one of the Funanese dynasties concurrent with ចន្ទវង្ស)
ស៊ុះ	thoroughly

សុះសាយ	all over
ស៊ូ	courageous, tough, persistent
ស៊ូ + v.	would rather + v. + instead
ស៊ូ... ជាជាង	rather ... than
ស៊ូស្លាប់ជាជាងចូលធ្វើទាហាន	(I'd) rather die than go to serve in the military service.
សូក	to bribe
សូកប៉ាន់	to bribe
ស៊ូក	shush, shh!
សូត្រ	to chant, recite
សូត្រ	silk
សូត្រធម៌	to chant prayers, recite scriptures
សូន្យ	nothing, zero
សូម	would like
សុមាត្រា	Sumatra
សូម្បី (តែ)	even; in spite of, including
សូរ	noise, sound
សូរ្យវរ្ម័ន	Suryavarman (name of famous Khmer kings)
សូវ	should, would rather
សូវ + v.	would rather + v. + instead, rather + v., better + v.
សួ	to walk on a horizontal pole or small bridge
សួត	lungs
សួន	garden
សួនច្បារ	garden, flower garden
សួនសត្វ	zoo
សួរ	to ask
សួរចម្លើយ	to interrogate
សួរដុច	to ask right to the main point, confront
សួរសុខទុក្ខ	to ask after someone, say hello to
សាកសួរ	to ask, inquire
សើច	to laugh
សើចទន់ខ្លួន	to laugh uncontrollably
សើ	superficial
សើៗ	superficially
សើរើ	to revise, review a case
ស៊ើប	to investigate
ស៊ើបសួរ	to investigate, find out
សើម	damp, humid, wet
សៀង	to swagger, be proud of oneself
សៀង	bean sauce, black bean sauce
សៀក	to carry in the belt
សៀម	Thai
សៀមរាប	Siem Rap (Cambodian province)
សៀវភៅ	book
សៀវភៅស៊ីក្លូ	registration book for a cyclo (unofficial usage)
សេចក្តី	affair, matter, connotation, meaning, sense; contents, story, verb or adjective nominalizer
សេចក្តីក្លាហាន	bravery, courage
សេចក្តីព្រាង	draft
ឃ្លានេះមានសេចក្តីយ៉ាងម៉េច?	What does this sentence mean?
សេដ្ឋ	goods, property
សេដ្ឋកិច្ច	economy
សេដ្ឋភណ្ឌ	object of value
សេដ្ឋសាស្ត្រ	economics
សេដ្ឋសាស្ត្រវិទូ	economist
សេសាស្រ	dawn (literary)
សេន	cent, penny
សេនា	army (formal)
សេនាប្រមុខ	marshall (military rank)
សេនាសនៈ	a place to sleep and sit (often clerical)
សេព	to eat; to live off; to associate
សេពគប់	to associate with, be a member of the same crowd
សេរី	free
សេរីភាព	liberation

សេរីភាព	freedom
សេរ៉ូម	serum
សេវនៈ	association, intimacy
សេវនកិច្ច	association, act of making love, intercourse (formal)
សេអ៊ូល	Seoul
សេះ	horse
សែង	to carry (by two or more people)
សែន	hundred thousand; to sacrifice to spirits; to give a bribe (to spirits),
សែន	very..., really
មហាសែន	very very
សែនព្រេន	to sacrifice to spirits
សែប	boss, chief, sergeant (familiar) (French: chef)
សែសិប	forty
សៃលេន្ទ្រ	Sailendra (name of a Javanese dynasty)
សៃវៀន	(boxing) ring
សោ	lock; term to call one's sister-in-law
កូនសោ	key
ចាក់សោ	to lock; to unlock
សោក	to be sad, be unhappy
សោកសង្រេង	unhappy, sad
សោត	as for, thus
ប៉ុណ្ណឹងសោតក៏គាត់មិនដឹង	He didn't know even that.
សោធន	pension (literary)
សោភា	beautiful, good, grand (literary), beauty
សោភាភាព	beauty, goodness, high quality
សោម	moon (literary)
សោមវង្ស	Moon Dynasty (one of the Funanese dynasties, concurrent with សុរិយវង្ស)
សោមនស្ស	curious, interested, concerned, happy (formal)
សោយ	to eat (royal)
សោយទិវង្គត	to die (royal)
សោយទុក្ខ	to have troubles, worry, sad; grief
សោយរាជ្យ	to reign (king)
សោហ៊ុយ	cost, fee, price, tuition (money), expense, fare
សោះ	at all, to be completely out of
មិន...សោះ	not ... at all
សោះៈសេសាកិអស់	It's completely flavorless
សុំ	to ask for, beg
សុំខ្លួន	to volunteer
សុំច្បាប់	to ask for permission
សុំទឹកដំព្រះ	a ceremony in which water is placed before a Buddha image, prayed over, and then drunk or used to wash the face in the hope that it will bring luck or protect from danger
សុំទោស	Excuse me , I beg your pardon.
សុំសីល	to go to the wat on a day of abstinence to take food to the monks and participate in prayers
សុំអញ្ជើញ	please
សុំអញ្ជើញចូល	Please come in.
សំកុក	to sit or stand doing nothing
សំខាន់	important
សំគាល់	to have a remark, to observe
សំចត	to stop over for a short time; to park temporarily
សំដិល	to expose
សំដី	speech, utterance
សំដីផ្អែមល្ហក	nice and sweet words
សំដែង	to express (an idea), state
សំដៅ	to, toward
សំណ	lead
សំណប៉ាហាំង	tin
សំណង់	building, construction

សំណប់ចិត្ត	favorite
សំណល់	something left over
សំណាក់	place one lives occasionally; to live at a place
សំណាក់អាស្រ័យ	to stay
សំណាង	chance, luck
សំណាត់	something that drifts, drift (n.)
សំណាប	seedings before transplanting
សំណាល	to chat, converse
សំណេះសំណាល	to chat, converse
សំណឹក	erosion
សំណូក	bribe
ស៊ីសំណូក	to take a bribe, be corrupt
សំណូម	appeal, petition, request
សំណើច	laughter
អស់សំណើច	to make one laugh, burst into laughter
សំណើម	dampness, humidity
សំណៅ	copy (n.)
សំណុំ	bunch, chunk, piece, pile
សំណុំរឿង	case history, file, record of the case (used for courts)
សំនួរ	question
សំបក	husk, rind, shell, skin
សំបកកាក	ID card form
សំបុក	nest
សំបុត្រ	letter; ticket
សំបុត្រកំណើត	birth certificate
សំបុត្រឆ្លងដែន	passport
សំបុត្រទិញថ្នាំ	prescription (drugs)
សំបុត្រពេទ្យ	health certificate
សំបុត្រម្ចាស់ឡាន	car title
សំបុត្រឡាន	car registration
សំបុត្រអាសុរ៉ង់	insurance certificate
ស្រោមសំបុត្រ	envelope (for letter)
សំបូរព្រៃគុក	Sambour Prey Kauk (place with famous pre-Angkor ruins)
សំប៉ែត	flat (said of a thin object, e.g., disk)
សំផឹង	prostitute, whore
សំពង	to strike with a stick from behind the back and over the shoulder
សំពត់	cloth, dry goods; a kind of skirt
សំពត់ផាយរឹង	a skirt with a border
សំពត់ផាមួង	a sampot made of solid color silk
សំពត់សាលា	blue skirt worn with a white blouse as a uniform by schoolgirls
សំពត់ហូល	sampot made of pattern-dyed silk
សំពាយ	a bundle tied so that it can be carried slung from the shoulder under the arm
សំពឹក	slow-moving, stolid
សំពៀក	a bundle done up in a woven mat or hide
សំពះ	to greet with hands pressed together and raised to the face, a gesture of respect
សំពះពេល	a part of the traditional wedding ceremony
សំព្រូះ	in a visible manner
សំយុង	to hang down, hang straight down
សំរាក	to rest
សំរាប់	for, in order to
សំរាម	garbage, trash
សំរាល	to make lighter, lighten
សំរាលកូន	to deliver a child, give birth
សំរិត	to discard, refine
សំរុក	to lower
សំរើបចិត្ត	to excite, be aroused
សំរេច	to decide; to succeed
សំរែ	Sam Re (name of a montagnard tribe); bumpkin, country bumpkin

សំលៀកបំពាក់	clothing, dress (formal)
សំស្ក្រឹត	Sanskrit
សំឡាញ់	something loved, friend
សំឡី	cotton
សំឡឹង	to look at
សំឡេះ	to kill little by little
សំអប់	hatred
សំអាង(ទៅលើ)	something which one relies on, rely on
សំអាត	to clean up
សំអុយ	see ស្អុយ
សំអុយ	to cause to smell bad, stink
ស៊ាំ	to get used to
ខ្ញុំធ្វើការស៊ាំដៃ	
	I get used to working.
សាំង	to be tame; gasoline
សះ	cured, healed
សះស្បើយ	cured, healed
ស្កក	to be empty of contents, be only a shell, be unproductive
ស្ករ	sugar
ស្ករត្នោត	brown sugar which is sold in the form of discs
ស្កាត់	to go off the beaten track, lay a trap, waylay; to change the subject; to block, stop
ស្គម	meager, skinny, thin
ស្គម	skinny, thin (used only for humans and animals)
ស្គាំងស្គម	emaciated, skinny, thin
ស្គរ	a kind of drum
ស្គររយាល	name of a kind of Khmer marching music
ស្គាល់	to be acquainted with, recognize
ស្ងប់	to be in a lull
ការកំពុងស្ងប់	things are in a lull
ស្ងាត់	alone, quiet, without people
ស្ងាប	to yawn
ស្ងួត	dry
ស្ងួន	adorable, something lovable
ស្ងើច	to admire
ស្ងៀម	to be quiet, silent
ស្ងោរ	to boil; to make into soup; soup
ស្ញប់ស្ញែង	to be impressed, be awed, admirable
ស្តម្ភ	column; firm
ស្តាដ	stadium (French: "stade)
ស្តាប់	to listen
ស្តាប់បាន	to understand
ស្តាប់ឮ	to hear
ស្តាយ	to regret
សេចក្តីស្តាយ	regret
ស្តី	to scold, reprimand; to ask for a favor, request
ស្តីទិញកាហ្វេបន្តិចបានទេ ?	
	May I ask you to buy me some coffee?
ស្តីបន្ទោស	to reprimand
ស្តីអោយ	to blame, scold, reprimand
ស្តីទី	acting, pro tem
ស្តុក	a lot, many, much
ស្តុកស្តម្ភ	rich, wealthy
ស្តូក	extended and motionless
ស្តួច	slender, slim
ស្តួចស្តើង	few, scanty
ស្តើង	thin
ស្តេច	king, member of the royal family; sometimes used before a verb of motion if the king is the subject
ព្រះអង្គស្តេចយាងចេញមកហើយ	
	He (the king) is coming out now.
ស្តេចចង់	name of a traditional game
ស្តែង	apparent, clear, evident; dramatic, tragic
ស្តោះ	to spit
ស្តាំ	right (side)
ស្ត្រី	woman, women

ស្ត្រីបុត្រ	female child (literary), woman (in general)
ស្ថាន	location, place (formal) (a.w. ឋាន)
ស្ថានការណ៍	situation
ស្ថានទូត	embassy
ស្ថាននរក	hell
ស្ថានភាព	state of affairs
ស្ថានីយ	station (communication, transportation)
ស្ថានីយវិទ្យុ	radio station
ស្ថានីយរថយន្តយាន	railroad station, train station
ស្ថាប័ន	institution
ស្ថាប័នយោធា	national institution
ស្ថាប័នជាតិ	military institution
ស្ថាបនា	to build (formal)
ស្ថាពរ	definite, permanent (formal)
ជាស្ថាពរ	permanently
ស្ថិតនៅ	to be located at (formal)
ស្ថិតិ	records, statistics, custom, law; act of being located, life
ស្ទក់	slow, sluggish
ស្ទង់	to estimate, probe
ស្ទង់មើល	to survey
ស្ទាក់	to ambush, waylay
ស្ទាក់ភាយ	to ambush
ស្ទាក់ស្ទើរ	to be uncertain
ស្ទាត់	fluent, skillful, proficient
ស្ទាប	to touch
ស្ទឹង	small river
ស្ទឹងត្រែង	Stung Treng (Cambodian province)
ស្ទុង	hazy and indistinct, blur,
ស្ទុះ	to accelerate, burst forth, pick up speed, run at full speed, rush; to prosper
ស្ទូង	to transplant
ស្ទូច	to hoist, lift
ស្ទូចត្រី	to fish
ស្ទួយ	to lift, raise (by supporting from below); to indulge, spoil
ស្ទើរ	insufficient
ស្ទើរតែ	almost, barely
ស្ទៀង	Stieng (name of a montagnard tribe)
ស្នង	to be in the image of, represent; something returned
ស្នងការ	commissioner
ស្ន	spear
ស្នា	crossbow
ស្នាក់	to dwell, live at, stay for a short time; to seat (office)
ស្នាក់អាស្រ័យ	to dwell, stay at
ស្នាដៃ	handiwork, masterpiece, work (e.g., of art)
ស្នាព្រះហស្ថ	handiwork, masterpiece, work (royal)
ស្នាម	footprint, mark, print scar
ស្នាមភ្លោះ	ditch, moat
ស្និទ្ធ	to be on intimate terms with; really; to do well and conscientiously
ស្និទ្ធស្នាល	sincere, on close terms
ការស្និទ្ធស្នាល	sincerity
ញាំស្និទ្ធ	to consume with enjoyment
ស្នូក	trough; turtle's body
ស្នូកកាំភ្លើង	rifle butt
ស្នូរ	noise, sound
ស្នូល	core, pith, xylem; filler
ស្នើ	to advise, propose, suggest
ស្នៀត	tactics, technique, trick
ភ្លាត់ស្នៀត	to make a mistake
ស្នេហ៍	love charm
មានស្នេហ៍មួយ	charming
ត្រូវស្នេហ៍	to have a love charm put on someone

ស្នេហា	to love (poetic), love
ស្នេហាជាតិ	patriotic (literary)
ស្បង់	monk's sarong-like garment
ស្បថ	to swear
ស្បាត	custom; characteristic; way
ចាល់ស្បាត	to have learned one's lesson
ស្បូន	uterus, womb
ស្បូវ	a kind of long, coarse grass often used for thatch, sod
ស្បើយ	no longer ill, well (said when someone sneezes)
ស្បៀងអាហារ	food, provision
ស្បែក	hide, leather, skin
ស្បែកក្រាស់	callous, thin-skinned
ស្បែកគីង្គក់	goose bumps, goose pimples
ស្បែកជើង	shoe
ស្បែកភ្នែក	eyelid
ស្បោង	a small sack
ស្ពក	tray
ស្ព័រ្ត	sports
ស្ពាន	bridge
ស្ពាន់	copper
ស្ពាយ	to carry suspended from the shoulder
ស្ពាយកោធ្ងន់	to carry a heavy load on the back
ស្ពឹក	numb, without feeling; beriberi
ស្ពល	swollen
ស្ពៀក	deformed, misshapen
ស្ពៃ	cabbage, mustard greens
ស្ពៃក្ដោប	round cabbage
ស្ពៃស	Chinese cabbage
ស្ម័គ្រ	to volunteer
ស្ម័គ្រចិត្ត	to volunteer
ស្មា	shoulder
ស្មាតាន	see សមាតាន

ស្មាធិ	to become absorbed in an act or thought to the exclusivity of everything else
ស្មាន	to believe, guess, think
ស្មារតី	imagination, nerve, reflex
តាំងស្មារតី	to be alert, be at attention, pay attention
ស្មឹង	to be unconscious
ស្មឹងស្មាធិ	to meditate
ស្មុគស្មាញ	hairy, complicated and difficult
ស្មើ	to be equal, even
ស្មើគ្នា	alike, equivalent, equal, even
ស្មៀន	clerk, secretary
ស្មោគគ្រោក	dirty, filthy, nasty
ស្មោះ	honest, straightforward, faithful
ស្មោះត្រង់	honest, straightforward
ស្មោះស្ម័គ្រ	frank, straightforward
ស្មៅ	grass, weeds
ស្រក	to diminish, recede
ស្រកសាច់	to lose weight
ស្រក់	to drip
ស្រក់ទឹកមាត់	to make one's mouth water, salivate
ស្រកាក	in a messy manner
ស្រគត់ស្រគំ	to be blue, sad; quiet, silent
ស្រង់	to extract, pick out, esp. from water
ស្រង់	to bathe (a Buddha statue, divinity, clergy)
ស្រងាកចិត្ត	to be disappointed
ស្រងាត់	dull greenish colored; deserted, desolated
ស្រងូត	sad (facial expression)
ស្រងូតស្រងាត់	blue, melancholic, mournful, sad
ស្រងេះស្រងោច	to be sad; sadness
ស្រដី	to speak, say
ស្រដៀង	similar

ស្រណុក	comfortable, easy, good
ស្រទាប់	layer
ស្រទាប់ចេក	name of a piece of classical Khmer literature
ស្រប	consistent with, parallel, complied with
ស្របក	(spoken) bark, husk, shell (c.s. សំបក)
ស្របក់	a moment
ចាំមួយស្របក់	Wait a moment.
ស្រមុក	to snore
ស្រពេះ	sourpuss, unhappy (face)
ស្រមោច	ant
ស្រយាល	far (rare)
ស្រវឹង	drunk
ស្រស់	charming; fresh
ស្រស់ស្រាយ	to get over one's anger
ស្រស់ស្រុប	to eat (rural)
ស្រឡាង(សាឡាង)	ferryboat
ស្រឡាញ់	to love, be fond of
ស្រឡៃ	a kind of flute
ស្រឡាំងកាំង	to be appalled, to be in panic
ស្រឡះ	clear
មេឃស្រឡះ	clear sky
ស្រអែម	dark brown (used only of skin)
ស្រា	alcohol, liquor
ស្រាទំពាំងបាយជូរ	wine
បិតស្រា	to still alcohol
ស្រាត	to go naked, be naked, to take off clothing, streak
ស្រាប់	already, ready made
ស្រាប់តែ	suddenly
ស្រាពណ៍	name of the 9th lunar month (mid-July to mid-August)
ស្រាយ	to untie
ស្រាល	light
ស្រាវ	to haul in a rope, roll up string
ស្រាវជ្រាវ	to do research
ការស្រាវជ្រាវ	research
ស្រី	female, girl; lady, woman
ស្រីក្រមុំ	unmarried girl, young girl
ស្រីខូច	prostitute, whore
ស្រីពេស្យា	prostitute, whore
ស្រុក	city, district; country, village
ស្រុកខ្មែរ	Cambodia
ស្រុកទេស	country, nation
ស្រុកស្រែ	countryside, rural area
ស្រុកស្រែចំការ	countryside, rural area
ស្រុត	to cave in, sink, to collapse
ស្រុះ	altogether
ស្រុះគ្នា	altogether, all at the same time; united
ស្រូត	to hurry
ស្រូតឡើង	Hurry up!
ស្រូប	to pour soup over rice
ស្រស់ស្រូប	to eat, have a snack (rural)
ស្រូវ	uncooked, unmilled rice
ស្រូវកន្ទុះ	a fast-growing variety of rice that gives a small yield
ស្រូវដំណើប	glutinous rice
ស្រូវប្រាំង	dry-season rice
ស្រូវភ្នំ	upland rice
ស្រូវវស្សា	rainy-season rice
ស្រូវស្រាល	early-maturing rice
ស្រូវទឹកឡើង	a k.o. rice that grows well under flooded conditions
ស្រួច	sharp and pointed
ទាហានស្រួច	spearhead forces
ស្រួល	comfortable, easy
ស្រួលខ្លួន	to be well, be healthy
ស្រួលចិត្ត	to feel at ease; content, happy

ស្រួលបួល	comfortable, convenient, easy, right, well, carefully, orderly, properly
ស្រើប	to feel strong desire aroused
ស្រៀវ	to shiver
ស្រៀវស្រាញ	to shiver
ស្រេក	to be thirsty
ស្រេកទឹក	thirsty
ស្រេច	already, complete
ស្រេចតែ	just, only
ស្រេចតែម្តង	forget it, no way, that's the end of it, completely shot
ស្រេច(តែ)លើ	to depend on, be up to
ស្រេចតែលើលោក	It's up to you.
ស្រេចនៅលើ	to depend on, be up to
ស្រេចហើយ	It's all wrong!
ស្រែ	rice field; countryside
ស្រែក	to shout, scream
ស្រោច	to sprinkle, water
ស្រោចទឹករំដោះគ្រោះ	a [illegible]emony in which monks sprinkle water and chant to avert foreseen danger or bad luck
ស្រោចស្រង់	to rescue, save, salvage
ស្រោម	case, envelope, sheath
ស្រោមជើង	sock, stocking
ស្រោមដៃ	glove, mitten
ស្រោមសំបុត្រ	envelope (for letter)
ស្រៈ	vowel
ស្រៈផ្សំ	diphthong
ស្រះ	a small pond, a man-made pond on the grounds of a wat, an ornamental pond
ស្រុះគ្នា	to do together
ស្ល	to stew
ស្លន់	to be in panic
ស្លន់ស្លោ	to be in panic
ស្លា	areca (tree) (fruit in part of betel that is chewed by old people)

ស្លាធម៌	a ceremonial ornament made with a banana tree trunk base
ស្លាធម៌ដូង	a ceremonial ornament made with a coconut base
ស្លាប	feather, wing
ស្លាបប៉ាកកា	pen (for writing)
ស្លាបព្រា	spoon
ស្លាបព្រាកាហ្វេ	coffee spoon
ស្លាប់	to die
ស្លាប់តែហោង	to die an unpleasant death
ស្លឹក	leaf; four hundred (old measurement for counting fruit)(see ផ្លូន)
ស្លឹកខ្ទឹម	scallion, spring onion
ស្លឹកគ្រៃ	lemon grass
ស្លឹកឆ្នោត	ballot
ស្លឹកឈើ	a leaf
ស្លឹកត្រចៀក	ear
ស្លូត	docile, tame
ស្លូតត្រង់	decent, of good character
ស្លេកស្លក់	sick and skinny
ស្លៀក	to put on a lower garment
ស្លៀកពាក់	to get dressed, be dressed
ស្លែ	algae, mold, slime
ស្លោ	to be pale with fear or illness
ស្លោក	to be burned; saying, slogan
ពាក្យស្លោក	saying, slogan
ស្លាំង	to be pale, be appalled
ភ័យស្លាំងមុខ	to be really afraid (the face turns pale instantly)
ស្វ័យប្រវត្តិ	automatic
ស្វា	monkey
ស្វាគមន៍	welcome
ស្វាធ្យាយ	to recite, study
ស្វាមី	husband (formal)
ស្វាយ	mango; gonorrhea, V.D.
ស្វាយរៀង	Svay Rieng (Cambodian province)

ស្វីស	Switzerland
ស្វេតច្ឆត្រ	a white umbrella (lit.)
ស្វែង	to look for, search for
ស្វះស្វែង	to look for, search for
ស្អប់	to hate
ស្អាត	beautiful, clean, nice
ស្អាតបាត	attractive, clean, well (dressed)
ស្អាតស្អំ	clean
ស្អិត	stick
ស្អី	what?, what sort of thing?
ស្អីហ្នឹង	What is that?
ស្អុយ	bad smelling, stinky, stenchy
ស្អូច	Saouc (name of a montagnard tribe)
ស្អែក	tomorrow
ខានស្អែក	day after tomorrow
ស្អែកឡើង	the next day
ស្អំ	to pat medicine on, treat therapeutically by heat

ហ

ហត់	fatigued, tired
ហត្ថ	hand (lit.); length from elbow to tip of middle finger
ហត្ថកម្ម	manual labor (formal)
ហត្ថករ	manual laborer
ហត្ថលេខា	signature (formal)
ហប់	stuffy
ហស់	too full (said of stomach)
ហស្ត	hand (royal)
ហស្តលេខា	signature (royal)
ហ៎	sentence-final particle that calls attention (familiar)
ហៀ	older brother (Chinese)
ហា	to open (said of mouth)
ហាមាត់	to open the mouth
ហាក់	to seem
ហាក់ដូចជា	it seems
ហាង	shop, store
ហាងឃ្លីង	Indian store
ហាងឆេង	a store that acts as a middleman
ហាងថ្នាំ	drug store
ហាងបាយ	restaurant
ហាត់	drill, exercise, practice
ការហាត់	drill (n.)
ហ្វឹកហាត់	to practise, train
ហ៊ាន	to be brave, dare
ហាន់	to cut into strips, slice
ហាម	to forbid, warn
ហាមមិនអោយ	to forbid + v.
ហាមមិនអោយធ្វើការធ្ងន់ទាំងអស់	He forbade me to do any heavy work.
ហាល	to dry, expose to the weather
ហាយប៊ី	dried shrimp
ហាសិប	fifty
ហិកតា	hectare (unit of metric land measurement equivalent to ten acres)
ហិត	to smell, sniff
ហិន	to be all gone (wasted)
ហិប	suitcase, trunk (a.w. ហឹប)
ហិរញ្ញ	currency, finance
ហិរញ្ញវត្ថុ	finance (fiscal)
ហី	to not care; represents a spoken pronunciation of ហើយ)
វាធ្វើហី	He's acting unconcerned. He's pretending not to know.
ហីន	cheap; small (lit.)
ហីនយាន	Hinayana (branch of Buddhism)
ហ៊ឹង	deafening
ហឹប	suitcase, trunk
ហ៊ឹះ	interjection of anger or desperation
ហ៊ឺះ	interjection indicating anger; sound of a groan
ហ៊ឺហា	fancy, flamboyant, showy
ហុកសិប	sixty
ហុច	to hand over, pass over
ហ៊ុន	share (e.g., of stock)

ក្រុមហ៊ុន	company (business)
ចូលហ៊ុន	to be a partner (in business)
ហ៊ុម	to surround
ហុយ	to rise like steam or smoke, to be dusty, to fume
ហូត	to pull out
ហូរ	to flow
ហូរកាត់	to flow through
ហូរចាក់	to flow into
ហូល	a type of handwoven fabric usually silk, in which the pattern is dyed into the threads before they are woven
ហូឡង់	Dutch
ហួច	to whistle
ហួញ	see (ដូរហួញ)
ហួត	to be dried up, be absorbed
ហួតហែង	to be dry, be dried up
ហួស	to exceed, surpass
ហួសចិត្ត	incredible, amazed
ហួសពេលហើយ	it's too late
ហួសហ្ក	to exceed one's capacity
ហួសសម័យ	out of date
ហួសហេតុ	beyond reason
ហើម	to swell, be swollen
ហើយ	well!, O.K.; already, and, then
ហើយឬនៅ	yet (question marker)
ហើរ	to fly (flapping wings)
ហៀរ	to overflow, be too much (said of liquid); to exceed
គាត់និយាយហៀរទឹកមាត់	He talks dribbling saliva.
ហៀប(នឹង) + v.	to be about to; almost
ហេង	to be lucky, be fortunate
ហេតុ	matter, reason
ហេតុការណ៍	cause, problem, trouble
ហេតុតែ	just because
ហេតុនេះបានជាយ៉ាងហ្នឹង	this is why
ហេតុផល	reason; consequence
ហេតុអ្វី	why?
ហេតុអ្វីខ្លះបានជា	why? (expects answer with several reasons)
មានហេតុ	something happens
ហេមន្ត	cool season, autumn (lunar calendar) (= ហេមន្តរដូវ)
ហេវ	tired, hungry
ហែ	to accompany in a procession, escort, march, parade
ហែខ្មោច	to have a funeral procession
ហែសព	to have a funeral procession
ហែក	to tear
ហែកកេរ្តិ៍	to destroy one's reputation by slandering him, reveal skeletons in the closet; to gossip
ហែង	dry
ហែល	to swim; to struggle
ហៃ	oh!
ហ៎ែ	attention-calling particle (familiar)
ហ៊ោ	to shout jubilantly
ហ៊ោកញ្ជ្រៀវ	to shout jubilantly
ហោង	indicates an end of a list or an issue
ហោចណាស់	at least
យ៉ាងហោចណាស់	at least
ហោប៉ៅ	pocket
ហោប៉ៅយួរ	handbag, purse
ហោរ	astrologer
ហោរា	astrologer; astrology, horoscope
ហោះ	to fly (mechanically)
ហៅ	to call, invite; to order
ហៅ + v. អីទេ	do you call that + v.?, how can you call that + v. ?

ហ៊ុំ-ហ៊ុំ	to encircle, surround
ហ៊ះ	question marker indicating anger
ហ្ន៎ះ	familiar final particle (= ណា៎)
ហ្នឹង	that, this, these, those
ហ្នឹងហើយ	that's right, yes
ហ្នឹងឯង	that's right, yes, so, thus thus
ចាំហ្នឹងហើយ	Wait here.
ហ៊ះហ្ន៎ះ	really (intimate)
ហ្ន៎ះ	you hear! (urges action) (non-formal)
ហ្ម	elephant driver, doctor, healer,
គ្រូហ្ម	doctor, healer
ហ្មត់ចត់	close, careful, with attention paid, meticulous, precise (a.w. ម៉ត់ចត់)
ហ្មត់ហ្មង	fine, small, smooth
ហ្មឹង	firm
ហ្មឹងហ្មាត់	serious, strict
ហ្វីល	film
ហ្វីលីពីន	Philippines
ហ្វឹកហ្វឺន	to drill, practise, train
ហ្វូង	herd, school (said of fish)
ហ្វូណន	Funan
ហ្វូស្វាត	phosphate
ហ្វ្រាំង	brake (French: frein)
ហ្សាការតា	Djakarta
ហ្សាវ៉ា	Java
ហ្សឺណែវ	Geneva
ហ្អ៎	familiar final question particle
ហ្អេះ	occurs at the end of a question (= ឬទេ)
ហ្អែង	you (intimate)

ឡ

ឡក	to make funny gestures
ឡាន	automobile, car
ឡានឈ្នួល	bus
ឡានទឹក	fire truck
ឡានពេទ្យ	ambulance
ឡាតាំង	Latin
ឡាយឡុង	to sell at auction
លក់ឡាយឡុង	to sell at auction
ឡូ	dozen
ឡូយ	arrogant, insolent
សំដីឡូយ	insolent words, arrogant words
ឡូឡា	to talk loudly
ឡើង	to go up, rise
v. + ឡើងវិញ	to do again, repeat; again
number + ឡើងទៅ	from (number) up, (number) or more
ពីរនាក់ឡើងទៅ	two or more people
ឡើងតាន	to get stuck up, get above oneself
(ឡើង)...ជា...	... to ..., ... times as much
ឡើង១ជា២	more than twice as much
ឡើងកោរ	to get a swollen head, show off
ឡើងឈាម	to have good color (not pale); to have high blood pressure
ឡើងថ្នាក់	to be promoted
ឡើងប្រាក់ខែ	to raise a salary
ឡើងសក្តិ	to enter a house
ឡើងផ្ទះ	to get promoted
ឡើងពាក្យ	to get stuck up, get above onself
ឡើងវិញ	again
ឡើយ	...at all...
ឡេវ	button
ឡេឡា	to be thrown into a panic
ឡោក	worn out (said of nuts, holes, etc.)
ឡោម	to ambush, surround
ឡោមព័ទ្ធ	to ambush
ឡោស៊ី	bolt
ដែកឡោស៊ី	bolt
ឡាំង	wooden case

អ-អ

អកុសល	unfortunate, unlucky
អក្ខរៈ	letter, consonant (a.w. អក្សរ)
អក្ខរាវិរុទ្ធ	orthography, spelling
អក្សរ	alphabet, consonant, letter
អក្សរសាស្ត្រ	literature
អគ្គ	exalted, high; general
អគ្គមហេសី	queen
អគ្គមេបញ្ជាការ	high command
អគ្គលេខាធិការ	secretary general
អគ្គលេខាធិការដ្ឋាន	secretary general
អគ្គស្នងការ	commissioner general
អគ្គី	fire (literary)
អគ្គិសនី	electricity (formal)
អង់គ្លេស	English (French: anglais)
អង់តែន	antenna (French: antenne)
អង់អាច	brave, fearless, strenuous
អង្ករ	rice (polished uncooked)
អង្ករបុក	rice which has been husked by pounding rather than milling
អង្ករសំរិត	completely milled rice
អង្ករសំរូប	milled but unpolished rice, brown rice
អង្កាល	when (future, question marker)
អង្កាលណោះ	that time
ពីអង្កាល	when? (past, question marker)
អង្កាម	shaft
អង្កេត	to investigate
អង្គ	corps; group; classifier for royalty, clergy, and deities
អង្គទូត	diplomatic corps
អង្គប្រជុំ	the assembled participants in a conference (formal)
អង្គការ	organization
អង្គការសហប្រជាជាតិ	United Nations Organization
លោកសង្ឃមួយអង្គ	a monk
អង្គតាសោម	Ang Tasom (name of a town in Takeo province)
អង្គរ	Angkor (name of the old capital)
អង្គរវត្ត	Angkor Wat
អង្គញ	sea bean; a kind of traditional game played with this fruit
អង្គប (អង្គុប)	trap
អង្គុយ	to sit down
អង្គុយគិតរក	to just be concerned about (also. អង្គុយរកគិត)
អង្គុយរក	to keep (doing exclusively)
អង្គុយលើចង្ក្រានលើកខ្លួនឯង	proverb: Don t be a social climber., to put onself up, be a social climber
អង្គុលីលេខ	typewriter
អង្រ្គី	(spoken) to shake, tremble (c.s. អង្រ្គឺ)
អង្វរ	to beg, plead
អង្សក	monk's inner garment, with a pocket
អង្សា	degree (temperature)

អង្អែល	to caress; to rub
អចិន្ត្រៃយ៍	permanent
អញ	I, me (non-formal)
អញនិយម	selfishness
អញ្ចឹង	in that case, so, then, therefore, well
អញ្ចុះ	like that (spoken usage)
អញ្ចេះ	like this (spoken usage)
លោកត្រូវនិយាយអញ្ចេះទើបត្រូវ	To be right, you must say like this.
អញ្ជើញ	to invite; please
លោកអញ្ជើញទៅណា?	Where are you going?
អញ្ជើញចូល	Please come in.
អឌ្ឍភាគ	half portion
អឌ្ឍមាស	semimonthly
អណ្ដាត	tongue
អណ្ដូង	well; mineshaft
អណ្ដូងរ៉ែ	mine, mine shaft
អណ្ដើក	turtle
អត់	to be patient, bear, put up with; no, not
អត់ទោស	pardon
អត់ប្រយោជន៍	futile, useless
អត់ផ្លូវ	there's no way
អត់មាន	to be out of, not to have
អត់អីទេ	It's nothing.
អតិ	too much (literary)
អតិបរិមា	maximum (literary)
អតិសុខុមប្រាណ	germ, microbe
អតីត	past, the past; ex-, former
អតីតកាល	the past
អតីតប្រធាន	ex-president, former president
អត្ត	self
អត្តទត្ថ	selfish
អត្តលេខ	identification number
អត្តសញ្ញាណប័ណ្ណ	ID card
អត្ថ	to explain; explanation translation; business, matter; result, thing; first, primary
អត្ថកថាដីកាយោគសា	name of a Buddhist scripture scripture
អត្ថន័យ	definition, meaning
អត្ថបទ	article, passage
អត្ថប្រយោជន៍	primary interest
អត្ថាធិប្បាយ	lecture; description
អចិរៈ	temporary (literary)
អធិការ	to administrate, inspect, administrator, chief, director, head, inspector (formal)
អធិបតី	to govern, preside; to sponsor
អធិបតីភាព	chairmanship, leadership
អធិបតេយ្យ	by power, sovereign (lit.)
អធិបតេយ្យភាព	sovereignty
អធិប្បាយ	to discuss, explain (as in an article)
អធិរាជ	emperor
អធ្យាស្រ័យ	to be understanding; mutual understanding
អធ្រាត្រ	midnight
អន់	to decrease; inferior, low; no good
អន់ចិត្ត	to feel bad, have bad feeling, to be upset
អន់ថយ	inferior; no good
អនាគត	future
អនាគតកាល	future time
អនាថា	bum
មនុស្សអនាថា	a bum
អនាធិបតេយ្យ	anarchy; disorder
អនាម័យ	hygiene
អនាមិក	anonymous
អនិច្ចកម្ម	to die; death
អនិច្ចា	alas! (obsolescent)
អនុ	under, vice
អនុកូល	see អនុគ្រោះ

អនុគ្រោះ	to help each other, support, sympathize
អនុញ្ញាត(អោយ)	to give permission; permission
អនុប្បវាទ	to abstain; neutral; abstention
ឆ្នោតអនុប្បវាទ	abstention vote
អនុប្រធាន	vice president
អនុពន្ធ	attaché
អនុម័ត	to approve; to decide (formal)
អនុលោម	to comply
អនុវត្ត	to apply, execute, follow
អនុវត្តន៍	application, execution
អនុវិទ្យាល័យ	junior high school
អនុសេនីយត្រី	2nd Lieutenant
អនុសេនីយទោ	1st Lieutenant
អនុសេនីយឯក	Captain (military)
អនុស្សាវរីយ៍	souvenir
អន្តរ:	prefix meaning: inter
អន្តរជាតិ	international
អន្តរាគមន៍	intervention
អន្តរាយ	disaster, disorder
អន្តិច	little (c.s. បន្តិច)
អន្ទាក់	trap
អន្ទាក់កាប់	name of traditional game
អន្ទះអន្ទែង	to show signs of severe pain or discomfort
អសុរិក្ខីយ៍	bestial
អន្លាយ	continuous, viscous
អន្លង់	ditch, hole, foxhole
អន្លូញ	a vertically striped silk used for skirts
អន្លើ	level, part, region
អន្សា	see រ៉ៃអន្សា
អប	to please someone
អបអរ	to approve heartily, be glad
គាអបគាត់ព្រោះគាចង់បានឡើងបុណ្យសក្តិ	He pleases him because he wants to be promoted.
អប់	to odorize

អប់រំ	to bring up, discipline, educate
អបរាជ័យ	victory
អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ	Pali for: ការមិនធ្វេស ប្រហែស គឺជាមាគ៌ានាំ អោយរស់ ការធ្វេសប្រហែស គឺជាផ្លូវទៅអោយស្លាប់
អប្រិយ	bad, nasty
អប្សរា	apsara: a heavenly dancer, attendant to the gods
អផ្សុក	to get bored; lonely
អ័ព្ទ	fog
អព្យា	unclear (literary)
អព្យាក្រឹត	neutral
អព្យាក្រឹតភាព	neutrality
អភ័ព្វ	unfortunate, unlucky
អភ័យ	to forgive
អភ័យទោស	to forgive, pardon
អភិ	extreme, high, very
អភិជន	a high-ranking person
អភិធម្ម	a teaching to initiate thinking
ខ្យល់អភិធម្ម	the breath of life
អភិបាល	chief, director, governor, head of an organization
អភិបាលខេត្ត	chief, governor (a.w. អភិបាលខេត្រ)
អភិវឌ្ឍន:	development
អភិវឌ្ឍនសហគមន៍	community development
អភិសេក	to crown; coronation (royal), a ceremony honoring a new Buddha image
អម	to assist
អមនុស្សធម៌	inhumanity; inhumane
អយស្ម័យយាន	locomotive
អយុត្តិធម៌	injustice; unjust
អរ	to be happy, be glad
អរគុណ	thank you
អរហំ	one who has succeeded in detaching himself from worldly desire (= អរហន្ត,

អរូបី	abstract
អរ្យៈ	civilized
អរ្យធម៌	civilization
អរ្យប្រទេស	civilized country
អរិយៈ	orderly, proper, very good
អរិយធម៌	civilization
អរិយប្រទេស	civilized country (literary)
អរុណ	morning (formal)
អលង្ការ	jewelry
អវិរុទ្ធ	correct, not wrong
អវិភក្កបី	obedience to the law
អស់	to be finished, be out of, to be used up, run down; all of, entirely
អស់កម្លាំង	to be tired, exhauted
អស់ចិត្ត	to give up (stop hoping) to be satisfied
អស់ពីចិត្ត	no reservation (without)
អស់រលីង	completely gone
អស់លោក	all you gentlemen
អស់លោកធំៗ	all the important people
អស់លោក-លោកស្រី	ladies and gentlemen
អស់លោកអ្នក	ladies and gentlemen
អស់សេចក្តី	exhaustive; complete
អស់សំណើច	to find something ridiculous
អស់សាំង	out of gas
អស់ហើយ	all gone, finished
អស់អាចម៍អស់នោម	completely, fully
អសន្តិសុខ	insecurity, disorder
អសុ	(prefix) bad, unpleasant
អសុរស	quarrelsome, unpleasant, bad
អសុរ	bad thoughts, evil person, enemy of the gods
អសុរកាយ	a ghost which walks at night.lives on unclean things, and haunts people
អសោច	foul smelling, smelling like a corpse
អស្ចារ្យ	great, magnificent
អស្សុជ	name of 11th lunar month (mid-September to mid-October)
អា	intimate or derogatory prefix
អាខ្ទេះ	fool, ignoramus
អាណា	which one?
អាណា	what, who, whom
អាណាក៏បាន	take anyone
អាណាហ្នឹង	who is that?
អាណុង	that one(colloquial)
អានេះ	this one, this
អានោះ	that one, that
អាប្រុស	nickname for a male child
អាប្រុស.	familiar address form for a male (intimate)
អាម៉ឺអាខាង	sycophant, toady
អាមួយហ្នឹង	the one
អាមួយនេះ	this one
អាយ៉ង	dummy, marionnette, puppet
អាស្រី	familiar address form for a female intimate
អាហានយៀ	bestial (referring to a bad person)
អាអើយ	vocative form used in addressing one with whom one is on familiar terms
អាឯង	you (intimate or contemptuous)
អាក់	to miss out, give up on
អាក់ចិត្ត	to feel bad, to be disappointed
អាក់អន់ចិត្ត	to be humiliated, be upset; to feel bad, have one's feelings hurt
អាកប្បកិរិយា	attitude, behavior, position
អាករ	heritage, inheritance
កេរ្តិ៍អាករ	heritage, inheritance
អាការៈ	letter of the alphabet; letter; missive
អាការ	condition, symptom
អាការសោហា	liquor, spirits

អាកាស	air, space, out of space
អាកាសចរណ៍	airline (formal)
អាកាសទេវតា	angel of the air
អាកាសធាតុ	climate, weather (= ធាតុអាកាស)
អាកាសយាន	airplane (formal)
អាកាសយានដ្ឋាន	airport (formal)
អាក្រក់	bad, unattractive, ugly; traumatic
ការពិសោធអាក្រក់	traumatic experience
អាគម	act of coming, act of entering; interrelation, into
អាគម	a spell
អាគារ	building
អាគុយ	a battery (car)
អាគាំង	American (colloquial)
អាគ្នេយ៍	southeast (literary) (= ទិសខាងកើតរវៀងទិសខាងត្បូង)
អាក្រាក់	big person (slang)
អាង	to be dependent on, to rely on
អាង	to depend on
អាង	basin, vat, tank
អាងថា+ clause	to depend on the fact that... just because ...
អាងបុណ្យស័ក្តិ	to take advantage of status to injure others
អាច	to be able
អាច	can, capable, possible
អាចម៍	excrement
អាចម៍គោ	manure
អាចម៍ត្រចៀក	ear wax
អាចម៍ច្រមុះ	snot
អាចម៍ដែកលួស	shavings
អាចម៍ភ្នែក	eye exudate
អាចម៍រណារ	sawdust
អាចម៍រុយ	freckles
អាចរិយ	teacher (a.w. អាចារ្យ)
អាចរិយវាទ	philosophy of the teacher
អាចារ្យ	layman who acts as liaison between monks of a wat and other lay people; also acts as a practitioner of traditional rituals; professor, teacher
អាជីវកម្ម	living, subsistence
អាជ្ញា	authority; law, power
អាជ្ញាគតិ	common law (literary)
អាជ្ញាកណ្តាល	arbitrary or intermediary mediator
អាជ្ញាធរ	authority
